ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី
ខេត្តបាត់ដំបង

លេខ:..០៥១៧./.២៦.../រប/ផនសស.បប

ថ្ងៃ.ចន្ទ.១៤..រោច.. ខែបឋមាសាឍ ឆ្នាំ.មមី.អដ្ឋ. ស័ក ព.ស២៥៧០
បាត់ដំបង,ថ្ងៃទី.......១៣........ខែ....កក្កដា......ឆ្នាំ២០២៦

## សេចក្តីជូនដំណឹង
## ស្តីពី
## ការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ
## ភូមិស្វាយជ្រុំ ភូមិព្រៃកគាំព្រែង និងភូមិព្រៃកក្រូច ឃុំព្រៃកនរិន្ទ ស្រុកឯកភ្នំ ខេត្តបាត់ដំបង

យោងតាមអនុក្រឹត្យលេខ៤៦អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី និងអនុក្រឹត្យលេខ១២២អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល មាត្រា៦ មាត្រា៧ និងមាត្រា១១ នៃអនុក្រឹត្យលេខ៤៦អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី។ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបាត់ដំបង សូមជូនដំណឹងដល់សាធារណៈជន ម្ចាស់ក្បាលដី ព្រមទាំងគ្រប់មន្ទីរអង្គភាព និងស្ថាប័ន ឬភ្នាក់ងារហិរញ្ញវត្ថុ ដែលមានការពាក់ព័ន្ធនឹងក្បាលដីទាំងអស់ ដែលស្ថិតក្នុងតំបន់វិនិច្ឆ័យនៃ**ភូមិស្វាយជ្រុំ ភូមិព្រៃកគាំព្រែង និងភូមិព្រៃកក្រូច ឃុំព្រៃកនរិន្ទ ស្រុកឯកភ្នំ ខេត្តបាត់ដំបង** ឱ្យបានជ្រាបថា ដើម្បីអនុវត្តតាមខ្លឹមសារនៃអនុក្រឹត្យយោងខាងលើ គណៈកម្មការរដ្ឋបាលនឹងធ្វើការបិទផ្សាយជាសាធារណៈនូវឯកសារសុរិយោដី ដែលមានប្លង់សុរិយោដី និងបញ្ជីឈ្មោះអ្នកកាន់កាប់ដី ដែលក្រុមការងារចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធបានធ្វើការវាស់វែង និងប្រមូលទិន្នន័យកន្លងមក។

ហេតុដូចបានជម្រាបជូនខាងលើ សូមសាធារណៈជន និងអង្គភាពនានា ដែលមានការពាក់ព័ន្ធនឹងដីធ្លីក្នុងតំបន់វិនិច្ឆ័យខាងលើ មេត្តាចូលរួមពិនិត្យលើទិន្នន័យ ដែលមាននៅក្នុងឯកសារនៃការវិនិច្ឆ័យ ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវ ឬ ខុសឆ្គង ដែលត្រូវកែតម្រូវ ឬ ជំទាស់លើទិន្នន័យទាំងនោះក្នុងរយៈពេល១៥ថ្ងៃ (ដោយរាប់បញ្ចូលទាំងថ្ងៃឈប់សម្រាក) គិតចាប់ពីថ្ងៃទី..១៣...ខែ..កក្កដា..ឆ្នាំ..២០២៦ដល់ថ្ងៃទី..៤.....ខែ..សីហា....ឆ្នាំ..២០២៦..ជាកំហិត ស្ថិតក្នុងបរិវេណ**វត្តព្រៃកក្រូច ភូមិព្រៃកក្រូច ឃុំព្រៃកនរិន្ទ ស្រុកឯកភ្នំ ខេត្តបាត់ដំបង**។ ផុតរយៈពេលកំណត់ខាងលើ គណៈកម្មការរដ្ឋបាលសន្មតថាទិន្នន័យដែលបានបិទផ្សាយជូនពិនិត្យជាសាធារណៈនេះ មានភាពត្រឹមត្រូវហើយមិនអាចជំទាស់ ឬ តវ៉ានៅពេលក្រោយទៀតបានឡើយ។

**សូមបញ្ជាក់ថា** ផុតកំណត់នៃការបិទផ្សាយជាសាធារណៈ គណៈកម្មការរដ្ឋបាលនឹងធ្វើការបូកសរុប ហើយលើកសំណើផ្តល់សិទ្ធិលើអចលនវត្ថុទៅអភិបាលខេត្ត ដើម្បីពិនិត្យសម្រេច រួចបញ្ជូនឱ្យរដ្ឋបាលសុរិយោដី ចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ(ប័ណ្ណកម្មសិទ្ធិ) ជូនអ្នកកាន់កាប់ណា ដែលបំពេញគ្រប់លក្ខណៈតាមផ្លូវច្បាប់។

គណៈកម្មការរដ្ឋបាលនឹងដាក់ទីតាំងបណ្តោះអាសន្ន នៅកន្លែងបិទផ្សាយ ដើម្បីរង់ចាំទទួលពិគ្រោះ និងផ្តល់យោបល់ដល់អ្នកដែលមានសំណូមពរ។

**ចម្លងជូន**

- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋបាលខេត្តបាត់ដំបង
- កម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី

"ដើម្បីគោរពជូនជ្រាប"

- មន្ទីរអង្គភាពនានាជុំវិញខេត្ត
- រដ្ឋបាលស្រុកឯកភ្នំ
- គ្រប់ធនាគារ និងអង្គភាពហិរញ្ញវត្ថុ

"ដើម្បីសហការអនុវត្ត"

- ឯកសារ-កាលប្បវត្តិ

**ប្រធានមន្ទីរ**

សួន_សុភា